# គោលការណ៍ណែនាំ

# ស្ដីពី

# ការដាក់ឱ្យអនុវត្ត

# សាកល្បងអត្តាភាពថវិកា

# មាតិកាសំខាន់ៗ

I. សេចក្តីផ្តើម
   1. សាវតា
   2. គោលបំណង

II. ក្របខណ្ឌអង្គភាពថវិកា
   1. និយមន័យ
   2. រចនាសម្ព័ន្ធ
   3. លក្ខខណ្ឌវិនិច្ឆ័យ
   4. អត្ថប្រយោជន៍

III. នីតិវិធីក្នុងការរៀបចំអង្គភាពថវិកា

IV. ការដាក់ឱ្យអនុវត្តអង្គភាពថវិកា
   1. យុទ្ធសាស្ត្រនៃការដាក់ឱ្យអនុវត្តអង្គភាពថវិកា
   2. ផែនការសកម្មភាពដើម្បីដាក់ឱ្យអនុវត្តអង្គភាពថវិកា
   3. ការបំពេញតារាងតាមជំហាននីមួយៗ

V. សេចក្តីសន្និដ្ឋាន និងបញ្ហាប្រឈម
   1. សេចក្តីសន្និដ្ឋាន
   2. បញ្ហាប្រឈម

# I. សេចក្តីផ្តើម (ត)

## 1. សាវតា

- បន្ទាប់ពីបានអនុវត្តដំណាក់កាលទី១ នៃការបង្កើនភាពជឿទុកចិត្តលើថវិកាប្រកបដោយជោគជ័យចាប់ពីចុងឆ្នាំ២០០៤ រហូតមកដល់ចុងឆ្នាំ២០០៨។ តែចំNuចសំខាន់ក្នុងជំហានទី២ នេះ គឺការដាក់ឱ្យអនុវត្តអង្គភាពថវិកា ដើម្បីលើកកំពស់ប្រសិទ្ធភាពការងារ និងគណនេយ្យភាពហិរញ្ញវត្ថុ។
- កសហវបានរៀបចំឯកសារក្របខណ្ឌស្តីពីការរៀបចំអង្គភាពថវិកាដែលជាមូលដ្ឋានសម្រាប់ ការរៀបចំរចនាសម្ព័ន្ធអង្គភាពថវិកានៅតាមក្រសួង ស្ថាប័ន និងគោលការណ៍ណែនាំស្តីពីការដាក់ឱ្យអនុវត្តសាកល្បងក្របខណ្ឌអង្គភាពថវិកា ដើម្បីជាមូលដ្ឋានសម្រាប់ការដាក់ឱ្យអនុវត្តសាកល្បងជាមួយក្រសួង១០ នៅក្នុងឆ្នាំ២០១៥។

# I. សេចក្តីផ្តើម (ត)

## 2. គោលបំណង

- ផ្តល់ជាមូលដ្ឋានដល់គ្រប់ក្រសួង ស្ថាប័ន សម្រាប់ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន ប្រកបដោយភាពស័ក្តិសិទ្ធិ ក្នុងការពង្រឹងការគ្រប់គ្រងថវិការបស់ខ្លួន ឆ្ពោះទៅរកប្រព័ន្ធថវិកាផ្តោតលើលទ្ធផល។
- គឺសម្រាប់ចង្អុលបង្ហាញដល់ក្រសួងសាកល្បងទាំង ១០ ក្នុងការរៀបចំរចនាសម្ព័ន្ធអង្គភាពថវិកា ដើម្បីត្រៀមអនុវត្តសាកល្បងនៅក្នុងឆ្នាំ២០១៥។

# II. ក្រុមខណ្ឌអន្តរាគមន៍វិបត្តិ

## 1. និយមន័យ

- ជាអង្គភាពដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាល និងស្ថិតក្នុងរចនាសម្ព័ន្ធក្រសួងស្ថាប័ន។
- ជាអង្គភាពដែលទទួលអាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាព ដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់។
- ជាអង្គភាពដែលមានសមត្ថភាពក្នុងការទទួលខុសត្រូវ។
- ជាអង្គភាពដែលមានភាពជាម្ចាស់ ក្នុងការរៀបចំ និងគ្រប់គ្រងវិបត្តិ។
- ជាអង្គភាពដែលមានការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារ។

# II. ក្របខណ្ឌអន្តរកាលថវិកា (ត)

## 2. រចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន

ការពិនិត្យឡើងវិញលើរចនាសម្ព័ន្ធបច្ចុប្បន្ន

- ត្រូវពិនិត្យលើអាណត្តិកិច្ចនិងមុខងារភារកិច្ច និងពិនិត្យលើរចនាសម្ព័ន្ធបច្ចុប្បន្ន និងការកែលម្អទាំង៣កម្រិតឱ្យមានភាពត្រឹមត្រូវរវាងកម្រិតទាំង៣។
- ត្រូវពិនិត្យលើមូលដ្ឋាននៃរចនាសម្ពន្ធដែលមាន៣កម្រិត ដូចជាកម្រិតដឹកនាំ និងកំណត់គោលនយោបាយ (កម្រិត១) កម្រិតបច្ចេកទេសនិងកំណត់យុទ្ធសាស្ត្រ (កម្រិត២) កម្រិតបច្ចេកទេសនិងអនុវត្តសកម្មភាព (កម្រិត៣)
- កម្រិតទី៣ នេះ **ជាកម្រិតអន្តរកាលថវិកា** ប៉ុន្តែគឺអាស្រ័យលើស្ថានភាពរចនាសម្ព័ន្ធ ស្ថាប័នរបស់ក្រសួង ស្ថាប័ន។

# II. ក្របខណ្ឌអង្គភាពថវិកា (ត)

## 2. រចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន (ដ្យាក្រាម១)(ត)



# II. ក្របខណ្ឌអង្គភាពថវិកា (ត)

## 3. លក្ខខណ្ឌវិនិច្ឆ័យ

- ជាអង្គភាពរដ្ឋដែលទទួលបានថវិកាតាមរយៈប្រព័ន្ធថវិការដ្ឋ។
- អង្គភាពស្ថិតក្នុងកម្រិត៣ នៃរចនាសម្ព័ន្ធ និងត្រូវកំណត់មុខងារ និងភារកិច្ច ព្រមទាំងមានបន្ទាត់គណនេយ្យភាពត្រឹមត្រូវ។
- មានទំហំសមស្រប និងប្រកបដោយនិរន្តរភាព (ទំហំការងារ ទំហំតម្រូវការបុគ្គលិក និងទំហំតម្រូវការថវិកា)។
- មានសមិទ្ធិកម្ម ឬលទ្ធផលក្នុងឆ្នាំ និងចុងក្រោយ នៅក្នុងកម្រិតដែលអាចវាស់បាន
- មានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពការងារ ផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំ។
- មានភាពជាម្ចាស់ក្នុងការគ្រប់គ្រងដឹកនាំ។
- ការវិភាជន៍ថវិកាប្រចាំឆ្នាំ និងការទទួលខុសត្រូវក្នុងការអនុវត្តការងារ។

# II. ក្របខណ្ឌអន្តរាពជថវិកា (ត)

## 4. អត្ថប្រយោជន៍

❖ អនុញ្ញាតឱ្យមានការបែងចែកមុខងារ និងការទទួលខុសត្រូវកាន់តែច្បាស់លាស់រវាងនាយកដ្ឋានហិរញ្ញវត្ថុ (អ្នកវិភាជន៍ និងតាមដានការគ្រប់គ្រងថវិកា) និងនាយកដ្ឋានជំនាញ ឬអង្គភាពផ្គត់ផ្គង់សាធារណៈ (អ្នកប្រើប្រាស់ និងគ្រប់គ្រងថវិការបស់ខ្លួន)។

❖ ជំរុញបង្កើនតម្លាភាព និងគណនេយ្យភាពក្នុងការអនុវត្តការងារតាមក្រសួង ស្ថាប័ន។

❖ អនុញ្ញាតមានការរៀបចរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលការងារ។

❖ អនុញ្ញាតមានការរៀបចំ និងវិភាជន៍ថវិកាកាន់តែប្រសិទ្ធភាពជាងមុខ ពិសេសការផ្សារភ្ជាប់ថវិកាទៅនឹងលទ្ធផលកាន់តែប្រសើរជាងមុន។

❖ បង្កលក្ខណៈងាយស្រួលដល់ការរៀបចំចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់រដ្ឋបាលការអនុវត្តថវិកាកម្មវិធី និងថវិកាសមិទ្ធកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុតាមពត៌មានវិទ្យា។

# II. ក្របខណ្ឌអង្គភាពថវិកា (ត)

## 4. អត្ថប្រយោជន៍ (ត)

- ជំរុញឱ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងច្បាស់លាស់ ពិសេសងាយស្រួលដល់ការរៀបចំយន្តការត្រួតពិនិត្យការអនុវត្តថវិកា លទ្ធផលសកម្មភាពការងារ និងសមិទ្ធិកម្មបានកាន់តែប្រសើរជាងមុន។
- ជំរុញឱ្យមានភាពទទួលខុសត្រូវ និងភាពជាម្ចាស់ក្នុងការអនុវត្តការងារដែលបានប្រគល់ដោយក្រសួងស្ថាប័ន។
- ជំរុញឱ្យបង្កើនសមត្ថភាពជំនាញរបស់អង្គភាព និងបង្កើតរចនាសម្ព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យលទ្ធផលការងារកាន់តែមានភាពច្បាស់លាស់។
- ចូលរួមចំណែកឱ្យក្រសួងស្ថាប័នគ្រប់គ្រង និងអនុវត្តការងារបានកាន់តែប្រសើរជាងមុន។

# III. នីតិវិធីក្នុងការរៀបចំអន្តរភាពថវិកា

❖ **ជំហានទី១ ការពិនិត្យលើបេសកកម្ម អាណត្តិកិច្ច និងគោលបំណងគោលនយោបាយ÷**

- ក្រសួងគួរពិនិត្យឡើងវិញលើច្បាប់អនុក្រឹត្យ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងកាកំណត់បេសកកម្ម មុខងារ និងការទទួលខុសត្រូវទាំងមូលរបស់ខ្លួន (បំពេញតារាងទី១)
- ប្រសិនបើមុខងារ និងភារកិច្ចមិនមានសង្គតិភាពទៅនឹងកម្មវិធី អនុកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព និងគោលបំណងគោលនយោបាយទេនោះ ក្រសួងគួរធ្វើការពិនិត្យឡើងវិញ (ក្រសួងគួរយោងទៅលើដ្យាក្រាម១)

❖ **ជំហានទី២ ការពិនិត្យលើរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នបច្ចុប្បន្ន**

- ការកំណត់ឱ្យបានច្បាស់លាស់នូវបន្ទាត់គណនេយ្យភាពរវាងកម្រិតនីមួយៗដូចមានបង្ហាញនៅក្នុងដ្យាក្រាមទី១។
- ក្រសួង ស្ថាប័ន បំពេញតារាងទី២ ស្ដីពីរចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន និងតារាងទី៣ ស្ដីពីការផ្សារភ្ជាប់រចនាសម្ព័ន្ធគ្រប់គ្រងទៅនឹងរចនាសម្ព័ន្ធគោលនយោបាយ។

# III. នីតិវិធីក្នុងការរៀបចំអង្គភាពថវិកា (ត)

- គួរផ្តោតជាសំខាន់ទៅលើកម្រិត៣ ជាកម្រិតដែលត្រូវរៀបចំឱ្យទៅ**ជាអង្គភាពថវិកា។**

❖ **ជំហានទី៣ ការពិនិត្យនិងវាយតម្លៃលើអង្គភាពដែលអាចក្លាយជាអង្គភាពថវិកា**

- វាយតម្លៃទៅលើអង្គភាពកម្រិត៣ ដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យទាំង៧។
- ក្រោយពីក្រសួង ស្ថាប័ន បានវាយតម្លៃទៅលើអង្គភាពកម្រិតទី៣ រួចមក ក្រសួង ស្ថាប័ន ត្រូវបញ្ចូលអង្គភាពទាំងនោះទៅក្នុងតារាងទី៤ នៃឧបសម្ព័ន្ធ១ ហើយតារាងទី៤ នឹងជួយក្នុងការស្វែងរកចំណុចសម្រាប់ត្រូវកែលម្អ។
- តារាងនេះគួរត្រូវបានបំពេញដោយក្រុមការងាររៀបចំថវិកា ពិសេសត្រូវមានការចូលរួមពីនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងនាយកដ្ឋានជំនាញ ហើយគួរត្រូវបានត្រួតពិនិត្យនិងឯកភាពដោយអគ្គលេខាធិការឬអគ្គនាយកដែលទទួលបន្ទុកគ្រប់គ្រងរួម ព្រមទាំងអនុម័តដោយប្រធានស្ថាប័ន មុននឹងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# III. នីតិវិធីក្នុងការរៀបចំអង្គភាពថវិកា (ត)

❖ **ជំហានទី៤ ការរៀបចំបង្កើតអង្គភាពថវិកា**

- ក្រសួង ស្ថាប័នអាចវាយតម្លៃទៅលើអង្គភាពដែលមិនទាន់សមស្របទៅនឹងលក្ខខណ្ឌ វិនិច្ឆ័យទាំង៧ ។
- គឺជាការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវ ក្នុងការគ្រប់គ្រងថវិកា រវាងនាយកដ្ឋានហិរញ្ញវត្ថុ (អ្នកចាត់ចែងគ្រប់គ្រងថវិកា) និងនាយកដ្ឋានជំនាញ (អ្នកប្រើប្រាស់និងអនុវត្តថវិកា)។
- ក្រសួង ស្ថាប័នបំពេញតារាងទី៥ ស្តីពីការរៀបចំផែនការសកម្មភាពសម្រាប់កែលម្អដែលមាននៅក្នុងឧបសម្ព័ន្ធ១ ដោយផ្អែកលើលទ្ធផលនៅក្នុងតារាងទី១ ដល់ទី៤។

# III. នីតិវិធីក្នុងការរៀបចំអង្គភាពថវិកា (ត)

❖ **ជំហានទី៥ ការរៀបចំ និងអនុម័តលើរបាយការណ៍ស្តីពីការរៀបចំអង្គភាពថវិកា**

- ក្រសួង ស្ថាប័នបូកសរុបលទ្ធផលពីជំហានទី១ ដល់ទី៤ កំណត់អ្នកទទួលខុសត្រូវ និងពេលវេលាសម្រាប់ការអនុវត្តសកម្មភាពដែលត្រូវកែលម្អ និងកំណត់អង្គភាពដែលអាចក្លាយជាអង្គភាពថវិកា។
- ក្រសួង ស្ថាប័នត្រូវបំពេញតារាងទី៦នៃឧបសម្ព័ន្ធ១ ស្តីពីរបាយការណ៍ស្តីពីការស្នើសុំអង្គភាពថវិកា។

❖ **ជំហានទី៦ ការត្រួតពិនិត្យ និងឯកភាពលើសំណើបង្កើតអង្គភាពថវិកា**

- គឺត្រួតពិនិត្យ និងឯកភាពលើសំណើបង្កើតអង្គភាពថវិការបស់ក្រសួង ស្ថាប័ន ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ធ្វើការវាយតម្លៃបូកសរុប និងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យលើសំណើសុំបង្កើតអង្គភាពថវិកាដើម្បីដាក់សុំការអនុម័តពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ត្រូវរៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ននីមួយៗ ដើម្បីដាក់ឱ្យអនុវត្តអង្គភាពថវិកាដែលបានអនុម័ត។

# IV.ការដាក់ឱ្យអនុវត្តអង្គភាពថវិកា

1. **យុទ្ធសាស្ត្រនៃការដាក់ឱ្យអនុវត្តអង្គភាពថវិកា**
   - ដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកាយ៉ាងហោចណាស់នៅក្រសួងសាកល្បងថវិកាកម្មវិធីទាំង១០ នៅឆ្នាំ២០១៥។
   - វាយតម្លៃការសាកល្បងអង្គភាពថវិកា និងការរៀបចំយុទ្ធសាស្ត្រពង្រឹង និងពង្រីកនៃឆ្នាំ២០១៦ ឬ២០១៧។
   - ឈានទៅអនុវត្តអង្គភាពថវិកាពេញលេញនៅឆ្នាំ២០១៨ ឬ២០២០
2. **ផែនការសកម្មភាពដើម្បីដាក់ឱ្យអនុវត្តអង្គភាពថវិកា**
   (មើលតារាងគំរូ)

# IV.ការដាក់ឱ្យអនុវត្តអង្គភាពថវិកា (ត)

## 3. ការបំពេញតារាងតាមជំហាននីមួយៗ

- តារាងទី១ រចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន (ជំហានទី១)
- តារាងទី២ រចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន (ជំហានទី២)
- តារាងទី៣ ការផ្សារភ្ជាប់រចនាសម្ព័ន្ធគ្រប់គ្រងទៅនឹងរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន (ជំហានទី២)
- តារាងទី៤ ការវាយតម្លៃតាមលក្ខខណ្ឌវិនិច្ឆ័យអង្គភាពថវិកា (ជំហានទី៣)
- តារាងទី៥ ការរៀបចំផែនការសកម្មភាពសម្រាប់កែលម្អ (ជំហានទី៤)
- តារាងទី៦ របាយការណ៍ស្តីពីការស្នើសុំអង្គភាពថវិការបស់ក្រសួង ស្ថាប័ន (ជំហានទី៥)

# V. សេចក្តីសន្និដ្ឋាន និងបញ្ហាប្រឈម

## 1. សេចក្តីសន្និដ្ឋាន

- ការដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា នឹងធ្វើឱ្យការបែងចែកមុខងារភារកិច្ច និងការទទួលខុសត្រូវកាន់តែមានភាពច្បាស់លាស់ រវាងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ (អ្នកគ្រប់គ្រងថវិកា) និងនាយកដ្ឋានជំនាញឬអង្គភាព ផ្តល់សេវាសាធារណៈ(អ្នកប្រើប្រាស់ និងអ្នកអនុវត្តថវិកា)។

# V. សេចក្ដីសន្និដ្ឋាន និងបញ្ហាប្រឈម (ត)

## 2. បញ្ហាប្រឈម

❖ **ការរៀបចំបង្កើតអង្គភាពថវិកា**

- រចនាសម្ព័ន្ធស្ថាប័នមានភាពខុសៗគ្នា។
- ការងារបណ្ដុះបណ្ដាលសម្រាប់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងមន្ត្រីកសហវ។
- បន្តការបណ្ដុះបណ្ដាលដល់មន្ត្រីនៃក្រសួង ស្ថាប័ន ៣០ ផ្សេងទៀត។

❖ **ការអនុវត្តអង្គភាពថវិកា**

- សមត្ថភាពក្នុងការរៀបចំ និងការគ្រប់គ្រងផែនការសកម្មភាពការងារ និងផែនការហិរញ្ញវត្ថុ ។
- សិទ្ធអំណាចក្នុងការដឹកនាំ គ្រប់គ្រង និងការទទួលខុសត្រូវសកម្មភាពការងារច្រើនពេក។
- សិទ្ធិអំណាចក្នុងការគ្រប់គ្រងរជ្ជទេយ្យ ដែលបានផ្ដល់ជូន

# សូមអរគុណ!